**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥៩៩ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៩

SCANNED

# ប្រកាស
## ស្តីពី
## ចំណាយរបស់សហគ្រាសដែលអនុញ្ញាតឱ្យកាត់កងនាក់និងនឹងពន្ធកាត់ទុក

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមការចាំបាច់នៃការងារគ្រប់គ្រងប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច ៖

ប្រការ ១.- យោងតាមមាត្រា ២៥ (ថ្មី) មាត្រា ២៦ (ថ្មី) មាត្រា ៤៧ មាត្រា ៤៨ និងមាត្រា ៤៩ (ថ្មី) នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ និងផ្អែកតាមផ្នែកទី ៥.៧.៣ នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ និងផ្នែកទី ៣.៣.៣ នៃប្រកាសស្តីពីពន្ធលើប្រាក់បៀវត្ស ចំណាយរបស់សហគ្រាសទាក់ទិននឹងពន្ធកាត់ទុកដែលអនុញ្ញាតឱ្យកាត់កង ឬមិនអនុញ្ញាតឱ្យកាត់កង ត្រូវបានកំណត់ដូចខាងក្រោម ៖

**១- ចំណាយចាត់ទុកជាបន្ទុករបស់សហគ្រាស ៖**

ប្រាក់ចំណាយដែលអ្នកជាប់ពន្ធនិវាសនជនបានទូទាត់ឱ្យអ្នកជាប់ពន្ធនិវាសនជន ឬអនិវាសនជន មុនការកាត់ទុកប្រាក់ពន្ធ គឺជាបន្ទុកចំណាយរបស់អ្នកជាប់ពន្ធដែលជាភ្នាក់ងារកាត់ទុក ។ បន្ទុកចំណាយនេះ ត្រូវបានអនុញ្ញាតឱ្យកាត់កងពីប្រាក់ចំណេញជាប់ពន្ធ ។

<u>ឧទាហរណ៍</u> ៖

សហគ្រាស "ក" បានជួលផ្ទះពីលោក "ខ" ក្នុងតំលៃ ១,០០០,០០០ រៀល ក្នុង១ខែ ។ ដូចនេះសហគ្រាស "ក" ត្រូវមានកាតព្វកិច្ចកាត់ទុកប្រាក់ពន្ធមុនការទូទាត់ថ្លៃឈ្នួលជូនលោក "ខ"។

- ប្រាក់ពន្ធកាត់ទុកស្មើនឹង ១,០០០,០០០ រៀល x ១០% = ១០០,០០០ រៀល
- ថ្លៃឈ្នួលដែលលោក "ខ" ទទួលបានស្មើនឹង ១,០០០,០០០ រៀល - ១០០,០០០ រៀល = ៩០០,០០០ រៀល
- ពន្ធកាត់ទុកដែលត្រូវបង់ជូនរដ្ឋបាលសារពើពន្ធគឺ ១០០,០០០ រៀល ។

ក្នុងករណីនេះទឹកប្រាក់ចំណាយសរុប ១,០០០,០០០ រៀល គឺជាបន្ទុករបស់សហគ្រាស "ក" ដែលអនុញ្ញាតឱ្យកាត់កងចេញពីប្រាក់ចំណេញជាប់ពន្ធ ។

**២- ចំណាយមិនចាត់ទុកជាបន្ទុករបស់សហគ្រាស ៖**

ប្រសិនបើអ្នកជាប់ពន្ធដែលជាភ្នាក់ងារកាត់ទុក មិនបានធ្វើការកាត់ទុកប្រាក់ពន្ធមុនការទូទាត់ ហើយបានបង់ពន្ធកាត់ទុកជូនរដ្ឋបាលសារពើពន្ធជំនួសអ្នកទទួលការទូទាត់ (រួមបញ្ចូលទាំងអត្ថប្រយោជន៍បន្ថែមដូចមានចែងក្នុងផ្នែកទី ៣.៣.៣ នៃប្រកាសស្តីពីពន្ធលើប្រាក់បៀវត្ស) ប្រាក់ពន្ធកាត់ទុកដែលបានបង់ជំនួសនេះ មិនត្រូវបានអនុញ្ញាតឱ្យកាត់កងពីប្រាក់ចំណេញជាប់ពន្ធទេ ។ ក្នុងករណីនេះ ចំណាយដែលបានទូទាត់ត្រូវបានអនុញ្ញាតឱ្យកាត់កងពីប្រាក់ចំណេញជាប់ពន្ធដោយគ្មានការបំប៉ោង (Gross Up) ឡើយ ។

<u>ឧទាហរណ៍</u> ៖

សហគ្រាស "ក" បានជួលផ្ទះពីលោក "ខ" ក្នុងតំលៃ ១,០០០,០០០ រៀល ក្នុង១ខែ ។ សហគ្រាស "ក" មិនបានកាត់ទុកប្រាក់ពន្ធមុនការទូទាត់ថ្លៃឈ្នួលជូនលោក "ខ" ទេ ។

- ថ្លៃឈ្នួលដែលលោក "ខ" ទទួលបានស្មើនឹង ១,០០០,០០០ រៀល
- សហគ្រាស "ក" ប្រកាសបង់ប្រាក់ពន្ធកាត់ទុកជូនរដ្ឋបាលសារពើពន្ធជំនួសលោក "ខ" ស្មើនឹង ១,០០០,០០០ រៀល x ១០% = ១០០,០០០ រៀល ។

ដូចនេះ ចំណាយលើថ្លៃឈ្នួលដែលទូទាត់ជូនលោក "ខ" ចំនួន ១,០០០,០០០ រៀល ត្រូវបានអនុញ្ញាតឱ្យកាត់កងពីប្រាក់ចំណេញជាប់ពន្ធ (មិនមែនទឹកប្រាក់ចំនួន ១,១០០,០០០ រៀល ឡើយ) ។ ចំពោះប្រាក់ពន្ធកាត់ទុកចំនួន ១០០,០០០ រៀល ដែលបានចំណាយបង់ជំនួសលោក "ខ" មិនត្រូវបានអនុញ្ញាតឱ្យកាត់កងចេញពីប្រាក់ចំណេញជាប់ពន្ធទេ ។

**ប្រការ ២.-** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣.-** អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសហគ្រាសដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យបានល្អប្រសើរ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**<u>ចម្លងជូន</u> :**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់សាលារាជធានី-ខេត្ត "ដើម្បីជូនជ្រាបជាពត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- កាលប្បវត្តិ-ឯកសារ